ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គជបជ
លេខៈ ០១១/១៧ អលខ.

# គោរពជម្រាបជូន
## លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍នៃគជបជ

**តាមរយៈ:** **ឯកឧត្តម អគ្គលេខាធិការ** នៃអគ្គលេខាធិការដ្ឋានគជបជ

**កម្មវត្ថុ:** របាយការណ៍កិច្ចប្រជុំពិភាក្សា ដើម្បីដំណើរការរៀបចំច្បាប់ស្តីពី "ការគ្រប់គ្រងការពពោះជំនួស" កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧។

**យោង:** លិខិតអញ្ជើញរបស់ក្រសួងកិច្ចការនារី លេខ ២០៧១ កកន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦

កាលពីថ្ងៃទីប្រាំ ខែមករា ឆ្នាំពីរពាន់ដប់ប្រាំពីរ វេលាម៉ោងពីររសៀល នៅសាលប្រជុំរបស់ក្រសួងកិច្ចការនារី មានរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីដំណើរការ**រៀបចំច្បាប់ស្តីពី "ការគ្រប់គ្រងការពពោះជំនួស"** ក្រោមអធិបតីភាព **លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**។ កិច្ចប្រជុំពិភាក្សារយៈពេល៣ម៉ោង បានដំណើរការតាមរបៀបវារៈសំខាន់ៗរួមមាន៖

- បទបង្ហាញរបស់ក្រសួងសុខាភិបាល ពាក់ព័ន្ធនិងសេចក្តីប្រកាស ដើម្បីទប់ស្កាត់ការពពោះជំនួស
- បទបង្ហាញរបស់ក្រសួងយុត្តិធម៌ តើច្បាប់ទប់ស្កាត់ការពពោះជំនួស គួរធ្វើឡើងក្នុងទិដ្ឋភាពណា ដើម្បីឲ្យស៊ីសង្វាក់និងបទដ្ឋានគតិយុត្តដែលមានជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា
- បទបង្ហាញរបស់ក្រសួងមហាផ្ទៃ ស្តីពីបច្ចុប្បន្នភាពនៃការពពោះជំនួស
- បទបង្ហាញពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីបទពិសោធន៍ជួបប្រទះក្នុងករណីការពពោះជំនួស
- បទបង្ហាញរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីទំនាក់ទំនងរវាងការសុំកូន និងការពរពោះជំនួស
- ពិភាក្សាស្តីពី ដំណើរការនៃការរៀបចំច្បាប់
- ពិភាក្សាពីតួនាទីភារកិច្ចរបស់ក្រុមការងារអន្តរក្រសួង

ជាកិច្ចចាប់ផ្តើម ***លោកជំទាវ រដ្ឋមន្ត្រី*** បានជម្រាបអង្គប្រជុំពីដើមហេតុនៃការចាប់ផ្តើមកិច្ចប្រជុំស្តីពីការពពោះ គឺបន្ទាប់ពីមានការភ្ញាក់ផ្អើលថាមានកើតឡើងក្នុងប្រទេសកម្ពុជា។ កិច្ចប្រជុំលើកទី១ បានធ្វើនៅក្នុងខែសីហា ឆ្នាំ២០១៦ ខាង UNFPA សុំឲ្យក្រសួងកិច្ចការនារី ជាអ្នករៀបចំកិច្ចប្រជុំអន្តរក្រសួងចង្អៀតព្រោះជាបញ្ហាស្ត្រី និងកុមារ ។ កាលណោះមានការចូលរួមដោយស្ថានទូតអូស្ត្រាលីដែលបានអះអាងថា ច្បាប់អូស្ត្រាលីអនុញ្ញាតឲ្យនាំចេញទារក និងមេជីវិត ដែលជាការផ្ទុយគំនិតគ្នា។

ក្រោយមកក៏មានកិច្ចប្រជុំលើកទី២ បានគិតថា គួតែមានច្បាប់មួយដែលត្រូវគ្រប់ដណ្តប់ និងស្របជាមួយច្បាប់ដែលមានស្រាប់ ដូចជាច្បាប់ផ្តប្បវេណី ច្បាប់សុំកូន និងច្បាប់ថ្មីរបស់ក្រសួងសុខាភិបាល។ នៅក្នុងកិច្ចប្រជុំនេះដែរ បានសម្រេចឲ្យក្រសួងកិច្ចការនារីជាអ្នកដឹកនាំរៀបចំច្បាប់។

ដើម្បីពន្លឿនការងាររៀបចំច្បាប់នេះបានឆាប់ គឺត្រូវការមានការគាំទ្រពីរាជរដ្ឋាភិបាល ដូច្នេះត្រូវស្នើសុំគោលការណ៍ចំនួន២ទៅ**សម្តេចនាយក**:

១. សុំគោលការណ៍រៀបចំច្បាប់ថ្មី ស្តីពីការពពោះជំនួស
២. សុំគោលការណ៍រៀបចំបង្កើតក្រុមការងារ ដែលមានការចូលរួមពី៧ក្រសួងសម្រាប់រៀបចំច្បាប់ថ្មីនេះ (ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ-នគរបាល ក្រសួងការបរទេស និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ។

ក្នុងថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧នេះ គឺជាកិច្ចប្រជុំលើកទី៣ ហើយក៏រាប់ជាកិច្ចប្រជុំលើកទីមួយនៃការរៀបចំច្បាប់។

តាមបទបង្ហាញរបស់ក្រសួងសុខាភិបាលដោយ**លោក ឆេង កាន់ណារ៉ាត់ ជាអនុប្រធានវិទ្យាស្ថានជាតិសុខភាពសាធារណៈ**ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សំកោសិកា ដាលិកា និងសរីរាង្គមនុស្ស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ គឺដោយសារមានការប្រញាប់ ព្រោះមានករណីផ្សាំប្តូរក្រលៀន ប៉ុន្តែបានគិតបន្ថែមចំនុចផ្សេងទៀត។ គិតកាលណោះ បញ្ហាពពោះ គឺមានភាពស្មុគស្មាញច្រើន ពាក់ព័ន្ធសីលធម៌ វប្បធម៌ សុជីវធម៌ គុណធម៌ ក៏សម្រេចទុកសិន ហើយដាក់ត្រឹមចំនុចប្រការ១២ នៅក្នុងប្រកាសដោយឡែកស្តីពីការគ្រប់គ្រងឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស ដែលចែងថា រាល់ការពពោះជំនួស ដែលជាសេវាមួយនៃកញ្ចប់សេវានានានៃការជួយឲ្យមានកូនតាមបែបបច្ចេកទេសវិទ្យាសាស្ត្រ (Assisted Reproductive Technology) ត្រូវហាមឃាត់ដាច់ខាត។ ការបរិច្ចាកមេជីវិត គឺត្រូវចេញដោយប្រកាសរបស់ក្រសួងសុខាភិបាល។ នៅក្នុងច្បាប់ គឺបានចែងថា ការផ្សាំអំប្រីយ៉ុង បានចំពោះតែគូស្វាមីភរិយាដែលមានបញ្ហាបង្កកំណើតប៉ុណ្ណោះ។ មិនអនុញ្ញាតដាក់ទៅក្នុងអ្នកដទៃទេ។ ឯការនាំចេញនាំចូលមេជីវិត ដាលិកា ឬសរីរាង្គ គឺត្រូវកំណត់ដោយក្រសួងសុខាភិបាល ហាមឃាត់ដាច់ខាតក្នុងគោលបំណងពាណិជ្ជកម្ម។

លោក ផុន ពុធបូរី ជាជំនួយការលោកជំទាវរដ្ឋមន្ត្រីបានរំលឹកអង្គប្រជុំ គួរតែពិនិត្យមើលទៅលើចំនុចៈ ប្តីឬប្រពន្ធជាជនជាតិដទៃ ប្តីប្រពន្ធជនជាតិខ្មែរមានលំនៅអចិន្ត្រៃយ៍នៅបរទេស និងអ្នកស្រឡាញ់ភេទដូចគ្នា។

ក្រសួងយុត្តិធម៌ដោយមិនបានរៀបចំត្រៀមដូចនេះមិនមានបទបង្ហាញទេ តែសុំពិនិត្យទៅលើផ្នែកគតិយុត្តនៃចំនុចនីមួយៗវិញ។ លោកជំទាវ អនុរដ្ឋលេខាធិការ បានលើកឡើងថា បើពិនិត្យទៅលើប្រការ១២ របស់ប្រកាស គឺបានសេចក្តីថា បិទផ្លូវដាច់ខាត ហើយប្រការ១១វិញគឺបានតែចំពោះគូស្វាមីខ្លួនឯងតែប៉ុណ្ណោះ បានសេចក្តីថា ច្បាប់ពពោះមិនអាចកើតឡើងបាន។ ប៉ុន្តែជាសំណាងល្អ គឺប្រកាសនេះមិនមានតំលៃគតិយុត្តគ្របដណ្តប់នោះទេ ដែលជាចំនុចយើងអាចពិចារណាបាន។

ឯកឧត្តម សូរ ឌីម៉ា ជាអនុប្រធានក្រុមប្រឹក្សានិតិកម្មនៃក្រសួងមហាផ្ទៃ លោកមានយោបល់ថា ចំពោះសមាជិកចូលរួមគួរមានជាតុ៣ទៀតដែលជាអ្នកអនុវត្តន៍ផ្ទាល់គឺ អគ្គស្នងការនគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ លោកជំទាវរដ្ឋមន្ត្រី ទទួលសំណើដើម្បីពិនិត្យពិចារណា។

បទបង្ហាញក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបង្ហាញពីបទពិសោធន៍ដែលបានជួបប្រទះកន្លងមកជុំវិញការជួលស្ត្រីខ្មែរឲ្យពពោះជំនួស គឺក្រសួងបានអនុវត្តទៅលើច្បាប់កុងស៊ុលៈ
១- ពិនិត្យនិត្យានុកូលកម្ម លើការនាំចេញ-ចូល ទារក ដោយយោងតាមប្រកាស១៨៣ ដែលត្រូវមានសំបុត្របញ្ជាក់កំណើតកូន លិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ក្រសួងការបរទេស និងលិខិតអនុញ្ញាតរៀបអាពាហ៍ពិពាហ៍របស់ក្រសួងមហាផ្ទៃ ក្រៅពីនេះក៏ពិនិត្យទៅលើសុពលភាពនៃលិខិតឆ្លងដែននិងទិដ្ឋាការ
២- កិច្ចសហការរបស់ស្ថានទូត ជាពិសេសទូតអូស្ត្រាលី។ ជាបញ្ហាគឺច្បាប់របស់អូស្ត្រាលី ទោះបីប្រជាជនកើតនៅទីណាក៏ដោយ ទូតគឺត្រូវចេញលិខិតឆ្លងដែនឲ្យ បើមិនដូច្នោះ ប្រជាជននិងប្តឹង។ ការដែលកំណត់ថាជាប្រជាជនអូស្ត្រាលីព្រោះស្ថានទូតបានផ្តល់សញ្ជាតិ តាមការពិនិត្យ DNA។ លោក ថូ សំណាង ប្រធាននាយកដ្ឋាននៃក្រសួងការបរទេស ក៏បានស្នើសុំឲ្យមាននិតិវិធី កោះហៅឳពុកម្តាយថ្មីរបស់ទារកមកធ្វើការសម្ភាសន៍ ដូចករណីស្នើរៀបអាពាហ៍ពិពាហ៍។

តាមជំនួបជាមួយស្ថានទូតអូស្ត្រាលីកន្លងមក ខាងស្ថានទូតបានបញ្ជាក់ថា ច្បាប់អូស្ត្រាលីមិនហាមឃាត់សេវាពពោះជំនួសទេ ទោះជាយ៉ាងណាខាងភាគីក្រសួងបានបញ្ជាក់ថា តាមច្បាប់ព្រហ្មទណ្ឌ ករណីនេះគឺខុសច្បាប់ និង

សុំឲ្យស្ថានទូតផ្អាកការផ្តល់លិខិតឆ្លងដែនដល់ទារក រហូតដល់មានដំណោះស្រាយថ្មី។ ករណីនេះខាងស្ថានទូតអាមេរិក ក៏បានបញ្ជាក់ថា ស្ថានទូតអាមេរិក មានគោលជំហរដូចស្ថានទូតអូស្ត្រាលីដែរ គឺ ឲ្យតែសាមីខ្លួនទាំងអស់ស្ម័គ្រចិត្ត ព្រមព្រៀង ហើយទារកមាន DNA ដូចឪពុក ឬម្តាយ ជាពលរដ្ឋអាមេរិក មានន័យថាទារកនោះមានសិទ្ធិទទួលបានលិខិតឆ្លងដែន ដោយមិនចាំបាច់ឆ្លងកាត់ការបញ្ជាក់ឯកសារអ្វីពីក្រសួងការបរទេសកម្ពុជានោះទេ។

សម្រាប់ច្បាប់របស់ប្រទេសនានាទាក់ទងនិងការពពោះជំនួស គឺ

- ប្រទេសដែលហាមឃាត់ដាច់ខាត មានចិន ជប៉ុន អារ៉ាប៊ីសាអូឌីត បារាំង បែលស៊ិក អ៊ីតាលី អេស្ប៉ាញ ទួគី កេបិច
- ប្រទេសដែលអនុញ្ញាតក្នុងករណីមានការស្ម័គ្រចិត្ត មានអូស្ត្រាលី អាមេរិក កាណាដា អង់គ្លេស វៀតណាម
- ប្រទេសដែលអនុញ្ញាតរវាងសាច់ញាតិឯង គឺប្រទេសប្រេស៊ីល
- ប្រទេសដែលអនុញ្ញាតទោះជាការរកប្រាក់ចំណេញ ឬដោយស្ម័គ្រចិត្ត មានរុស្ស៊ី ឥណ្ឌា នេប៉ាល់ អាហ្វ្រិកខាងត្បូង។

ជាបញ្ហាគឺភាពប្រលយមគ្នានៅក្នុងច្បាប់អន្តរជាតិឯកជន ( Conflit du Droit International Prive ).

នៅក្នុងបទបង្ហាញរបស់អគ្គលេខាធិការ គជបជ ដោយលោកជំទាវ រ៉ែន សិរីលក្ខិណា បានលើកឡើងពីហេតុការណ៍ដែលនាំអោយមានការភ្ញាក់ផ្អើលពីការពពោះ គឺនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ មានការបង្ក្រាបករណីអំពើផ្ញើអន្តរកាវីសម្រាប់ការពពោះជំនួស ដោយនគរបាលប្រឆាំងការជួញដូរមនុស្ស រាជធានី។ ដែលបច្ចុប្បន្ន ជនសង្ស័យកំពុងឃុំខ្លួន។ ជំនាញរកឃើញថា បទល្មើស នេះមានការឃុបឃិតរវាងជនជាតិអូស្ត្រាលី និងជនជាតិខ្មែរ២រូប បានល្បួងស្ត្រីខ្មែរឲ្យពពោះ និងផ្តល់កំរៃពី៨០០០ ទៅ១០០០០ដុល្លា។ ស្ត្រី៥២ នាក់ បានមកពិនិត្យសុខភាពដើម្បីបញ្ចូលមេជីវិត នៅមន្ទីរពេទ្យកម្ពុជា និងមន្ទីរពេទ្យវឌ្ឍនៈ មានតែ១២នាក់ទេដែលជោគជ័យ។ ជនសង្ស័យ ធ្លាប់បានប្រកករបរជួលស្ត្រីពពោះនេះនៅប្រទេសថៃ ឆ្នាំ២០១៣ បាន១៥នាក់ តែថៃបិទ ហើយបង្វែរមកកម្ពុជា មួយឆ្នាំហើយដែលបានទាក់ទងស្ត្រីចំនួន២៣នាក់ កើតកូនរួច៥នាក់ និងបានទារក៦នាក់ (ទារកភ្លោះមួយគូ)។ ជនសង្ស័យជាអន្តរការីទទួលពីអ្នកដែលចង់បានកូន ៥០០០០ដុល្លា។ កូនដែលកើតរួចបានធ្វើសំបុត្រកំណើត បំពេញបែបបទ អន្តោប្រវេសន៍ចេញទៅអូស្ត្រាលី (ស្ថានទូតបានផ្តល់សញ្ជាតិ) នៅសល់២នាក់មិនទាន់បានចេញ។

បញ្ហានេះមានច្បាប់មួយចំនួនពាក់ព័ន្ធ ហើយព្រះរាជអាជ្ញាបានចោទប្រកាន់តាមច្បាប់:

- ក្រមព្រហ្មទណ្ឌ: មាត្រា៣៣២ (អន្តរការរវាងអ្នកសុំកូន និងស្ត្រីពរពោះ) មាត្រា៦៣២ (សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត)
- ដោយការនាំចេញដែលធ្វើឡើងដោយអន្តរការីពុំមានអាណាព្យាបាលពិតប្រាកដ មកបំពេញបែបបទតាមផ្លូវច្បាប់ គឺអាចជាការរត់ពន្ធឬជួញដូរទារក
- ប្រកាសក្រសួងសុខាភិបាល លេខ៦៧៩ ប្រក/សនក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស (ប្រការ១២: រាល់ការពពោះជំនួស ដែលជាសេវាមួយនៃកញ្ចប់សេវានានានៃការជួយឲ្យមានកូនតាមបែបបទបច្ចេកទេសវិទ្យាសាស្ត្រ ត្រូវហាមឃាត់ដាច់ខាត។
- កម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញា កតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធសិទ្ធកុមារ សិទ្ធិមនុស្ស និងការប្រឆាំងឧក្រិដ្ឋកម្មនានា ដែលមិនអាចមើលរំលងករណីនេះបានឡើយ
- ករណីនេះជាសញ្ញាណនៃការជួញដូរមនុស្ស

ជាផលប៉ះពាល់ ស្ត្រីអាចយកការពពោះជំនួសជាមុខរបរ ដោយផ្អែកថាខ្លួនក្រីក្រ ;

- បញ្ហាសុខភាព - ការពពោះមានការប្រឈម កើតកូនដោយវះ(មានកំណត់ក្នុងកិច្ចសន្យារវាងអ្នកចង់បានកូន និងអ្នកពពោះ) កូនដែលគេបំបែកយកទៅធ្វើឲ្យម្តាយអ្នកបង្កើតធ្លាក់ទឹកចិត្ត។
- មនុស្សធម៌ធ្លាក់ចុះ - តម្លៃតាំងពីនៅក្នុងពោះ បើកូនល្អបានអោយថ្លៃពេញ បើកូនមិនពេញលក្ខណៈ អ្នកចង់បានកូនមិនយកឬទំលាក់ថ្លៃ

- កម្ពុជានិងអាចក្លាយទៅជាគោលដៅផលិតទារក
- សីលធម៌ធ្លាក់ចុះ - ស្ត្រីនៅលីវអាចចុះឈ្មោះជាអ្នកពពោះ
- និតិវិធីកន្លងមក ក្នុងករណីស្ត្រីពពោះមាននិតិសង្វាស មិនបានអនុវត្តមាត្រា៩៨៩ និងមាត្រា៩៩០ នៃក្រមរដ្ឋប្បវេណី ដែលស្វាមីរបស់ស្ត្រីអាចប្តឹងទំទាស់តវ៉ា.

  គណៈកម្មាធិការជាតិក៏បានដោះស្រាយដោយៈ
- បានរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួន៥លើក ក្នុងការឆ្លើយតបនិងបទល្មើសអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ
- ក្រសួងមហាផ្ទៃបានស្នើសុំភាគីអូស្ត្រាលី សហការជាមួយរដ្ឋាភិបាលកម្ពុជា លើបីចំនុចៈ

  ១- សុំអោយផ្អាកការស្នើសុំពពោះជំនួស ដើម្បីបង្ការកុំឲ្យមានករណីថ្មីកើតឡើង

  ២- ដោះស្រាយករណីដែលកំពុងមាន ដោយមានការសហការពីអ្នកចង់បានកូន ដោយទទួលខុសត្រូវធានាដល់សុវត្ថិភាពស្ត្រីពពោះ តាមដែលបានសន្យារួច

  ៣- រៀបចំនិតិវិធីរួមគ្នា ឲ្យបានសមស្រប ត្រឹមត្រូវ ដើម្បីដោះស្រាយករណីដែលកើតមានរួច។ ចំពោះករណីថ្មីត្រូវរងចាំការណែនាំថ្មីពីរាជរដ្ឋាភិបាល និងច្បាប់កំណត់
- រៀបចំការប្រជុំជាមួយអគ្គរាជទូតទាំងអស់ដែលមាននិវេសនដ្ឋាននៅកម្ពុជាដើម្បីបង្ហាញពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ និងដោះស្រាយអំពើពពោះជំនួស។

ជាព័ត៌មានបន្ថែមកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧ ប៉ូលីសអន្តោប្រវេសន៍ប្រទេសហ្វីលីពីនបានឃាត់ខ្លួនស្ត្រីជនជាតិហ្វីលីពីនចំនួន៤នាក់ ដែលមានបំណងមកពពោះនៅកម្ពុជា ហើយក៏បានដឹងថា មានស្ត្រី៥នាក់បានចាកចេញពីកម្ពុជាហើយ។ ក្រៅពីហ្វីលីពីន នៅមានជនជាតិដទៃដូចជា ជនជាតិថៃ ដែលបានមកពពោះនៅប្រទេសកម្ពុជា។

ចំពោះបទបង្ហាញរបស់ក្រសួងសង្គមកិច្ច ដោយលោកជំទាវ ច័ន្ទ ហាក់វត្តី រដ្ឋលេខាធិការក្រសួងសង្គមកិច្ច បានបញ្ជាក់ថា ការពពោះគឺខុសពីការសុំកូន គឺការសុំកូនគេធ្វើទៅលើទារក ឬកុមារដែលកើតហើយ និងមិនពាក់ព័ន្ធសាច់ឈាមជាមួយអ្នកស្នើសុំទេ។ ប៉ុន្តែ ចំពោះការពពោះជំនួស គឺពាក់ព័ន្ធការយកមេជីវិត មកដាក់ក្នុងខ្លួនអ្នកដទៃ។ ទោះជាយ៉ាងណា នៅពេលរៀបចំច្បាប់ពពោះ ក៏គួរមើលចំនុចខ្លះក្នុងច្បាប់សុំកូនដែលសមស្របដែរ។

នៅក្នុងរបៀបវារៈនៃកិច្ចពិភាក្សា លោកជំទាវអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌មានលើកថាតាមច្បាប់រដ្ឋប្បវេណី មាត្រា៩៨៧ ចែងពីមាតុភាព និងមាត្រា៩៨៨ ចែងពីបិតុភាព មើលទោះគឺខ្វាស់ជាមួយច្បាប់ពពោះដែលនិងរៀបចំ ។ ដូច្នេះយើងគួរពិនិត្យមើលថា តើគួររៀបចំបែបណា ឬត្រូវវិសោធនកម្មមាត្រាទាំងនេះ។

លោកស្រី សាខឿន សាវ៉ាតឌី អគ្គនាយករង បានលើថា បើពិនិត្យឲ្យច្បាស់ច្បាប់នេះមិនខ្វាស់ទេ។

លោកផុន ពុធបូរី ច្បាប់នៅប្រទេសដទៃ គឺមិនអនុញ្ញាតឲ្យប្រើអូវ៉ុល របស់ស្ត្រីពពោះទេ។

ជាសេចក្តីសម្រេចរួម គឺស្នើអោយក្រសួងកិច្ចការនារីរៀបចំគ្រោងឆ្អឹងច្បាប់នេះទាំងមូលព្រមទាំងបញ្ចូលនូវជាតុចូលផ្សេងៗចាំបាច់ រួចផ្ញើមកក្រសួងពាក់ព័ន្ធពិនិត្យនៅសប្តាហ៍ក្រោយ។

កិច្ចប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោងប្រាំសាមសិបនាទីរសៀល ក្រោមបរិយាកាសល្អក្នុងកិច្ចសហការផ្លាស់ប្តូរយោបល់ពីជំនាញនិមួយៗ។

អាស្រ័យហេតុនេះ សូមលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧

**អ្នកធ្វើរបាយការណ៍**

**រ៉ន សិរីលក្ខិណា**

បានឃើញ និងគោរពជូន

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាបជារបាយការណ៍

**អគ្គលេខាធិការ**

17.01.17

ឧត្តមសេនីយ៍ឯក.ថោង_សំអាត